**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
***Nation - Religion - King***

**ក្រសួងពាណិជ្ជកម្ម**
***Ministry of Commerce***
លេខ ២៧៣ ព.ណ.ឃ.ផ.ក.សក

# ប្រកាស

## ស្តីពីនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ

*******

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមស្មារតីអង្គប្រជុំអនុគណៈកម្មការសំរួលពាណិជ្ជកម្ម ដែលដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥ ។

# សំរេច

**ប្រការ ១ :** បែបបទនាំចេញទំនិញវាយនភ័ណ្ឌ និងសំលៀកបំពាក់ និងផលិតផលធ្វើពីស្បែក តាមប្រព័ន្ធអនុគ្រោះ MFN/GSP ត្រូវបានកំណត់ដូចខាងក្រោម :

ក-ការងារអធិការកិច្ចលើ ផលិតកម្ម និងផលិតផលនាំចេញត្រូវធ្វើដោយមន្ត្រីជំនាញរបស់ក្រសួងពាណិជ្ជកម្មនៅតាមមូលដ្ឋានផលិតកម្ម នៅក្រោយពេលទំនិញត្រូវបាននាំចេញ

រួចហើយ និងទទួលបានឯកសារបញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin " C/O " ) ពីក្រសួងពាណិជ្ជកម្ម ។

ខ- ដំណើរការអធិការកិច្ចនេះ គឺជាកាតព្វកិច្ចតំរូវអោយគ្រប់អ្នកនាំចេញត្រូវសហការណ៍ជាមួយមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីបញ្ជាក់ដំណើរផលិតកម្ម-សមត្ថភាពផលិតកម្ម-ការជួលផលិតធានាភាពសមស្របក្នុងការអនុវត្តន៍វិធានប្រភពដើមទំនិញ និងសំរាប់ជាមូលដ្ឋាននៃការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ នៅដំណាក់កាលបន្ទាប់ទៀត ។

គ- ការស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ តាមមធ្យោបាយផ្លូវទឹក និង ផ្លូវ អាកាស ត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនដូចខាងក្រោម :

- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ និងទីចាត់ការគយ និងរដ្ឋាករ
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading) ឬ Airway Bill ចំពោះ By Air
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)
- វិក័យប័ត្រ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- កិច្ចសន្យាទិញលក់ (Sale Contract)
- មូលប្បទានប័ត្រសំរាប់សោហ៊ុយរដ្ឋបាល និង កំរៃសំរាប់គ្រប់គ្រងការនាំចេញ

ឃ-ការស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញតាមផ្លូវអាកាស ក្រៅពីសហរដ្ឋអាមេរិក ត្រូវភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនដូចខាងក្រោម :

- វិក័យប័ត្រ (Invoice)
- តារាងបញ្ជាក់ពីការវេចខ្ចប់ (Packing List)
- កិច្ចសន្យាទិញលក់ (Sale Contract)
- មូលប្បទានប័ត្រសំរាប់សោហ៊ុយរដ្ឋបាល និង កំរៃសំរាប់គ្រប់គ្រងការនាំចេញ

+ នៅពេលទំនិញចេញរួច ត្រូវភ្ជាប់ឯកសារបន្ថែមដូចខាងក្រោម :

- កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញនាំចេញរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ និងទីចាត់ការគយ និងរដ្ឋាករ
- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមផ្លូវអាកាស (Airway Bill)
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)

ង-ការស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ទៅសហរដ្ឋអាមេរិក ដែលមានតំលៃក្រោម ៨០០ ដុល្លាអាមេរិក និងទៅសហគមន៍អឺរ៉ុបមានតំលៃក្រោម ៦០០០ អឺរ៉ូ ក្នុងការនាំចេញតាមជើងយន្តហោះតែមួយ ឬធ្វើការនាំចេញពេលតែមួយ ត្រូវបានលើកលែងមិនយកកំរៃអ្វីទាំងអស់ ប៉ុន្តែត្រូវភ្ជាប់មកជាមួយនូវឯកសារយោងដូចមានចែងតាមបណ្តាចំណុចខាងលើ ។

ច-ក្នុងករណីប្រទេសផ្តល់ប្រពន្ធ័អនុគ្រោះពាណិជ្ជកម្ម ត្រូវការយកអាជ្ញាប័ណ្ណនាំចេញ ( Export License "E/L " ) ជំនួសឱ្យ វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញវិញ នោះនីតិវិធី និងការយកកំរៃផ្សេងៗ របស់ E/L ត្រូវគិតដូច C/O Form N ។

**ប្រការ ២ :** បែបបទនាំចេញខាងលើត្រូវកំណត់អោយបង់សោហ៊ុយរដ្ឋបាល និង កំរៃគ្រប់គ្រងការនាំចេញ ដូចខាងក្រោម :

ក- វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ

* ទំរង់ N (Form N) = ៣០ USD ក្នុង ០១ ច្បាប់
* ទំរង់ A (Form A) = ៥០ USD ក្នុង ០១ ច្បាប់

ខ- ចំពោះទំនិញសំលៀកបំពាក់ ដែលមានបរិមាណក្រោម ២,000 Pieces ឬ ស្បែកជើងបរិមាណក្រោម ២០០ គូរ គឺ :

- វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ
  * ទំរង់ N (Form N) = ១០ ដុល្លាអាមេរិក ក្នុង ០១ ច្បាប់
  * ទំរង់ A (Form A) = ១៥ ដុល្លាអាមេរិក ក្នុង ០១ ច្បាប់

**ប្រការ ៣ :** ចាប់ពីពេលដាក់ពាក្យស្នើសុំនៅនាយកដ្ឋានប្រពន្ធ័អនុគ្រោះពាណិជ្ជកម្ម នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស នាយកដ្ឋានអាស៊ាននិងអង្គការអន្តរជាតិ រហូតដល់ការប្រគល់ឯកសារវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ មានរយៈពេល ១១ ម៉ោង ៥៥ នាទី នៃម៉ោងធ្វើការ ។

**ប្រការ ៤ :** កំណត់សុពលភាពនៃការប្រើប្រាស់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ By Air មានរយៈពេល ៣០ ថ្ងៃ ( សាមសិបថ្ងៃ ) ។

**ប្រការ ៥ :** នៅកន្លែងទទួលពាក្យរបស់នាយកដ្ឋានប្រពន្ធ័អនុគ្រោះពាណិជ្ជកម្ម និង នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ត្រូវមានការចូលរួមសង្កេតការណ៍ពីសំណាក់មន្ត្រីអធិការកិច្ចនៃក្រសួងពាណិជ្ជកម្ម និង តំណាងសមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា (GMAC) ដើម្បីតាមដានការបញ្ជាក់ការចុះថ្ងៃ-ខែ និង ពេលវេលាលើបង្កាន់ដៃទទួលពាក្យ និងលើឯកសារប្រគល់-ទទួលសំណុំរឿង ប៉ុន្តែមិនមានការជ្រៀតជ្រែកក្នុងកិច្ចការជំនាញរបស់នាយកដ្ឋានទេ ។

**ប្រការ ៦ :** ប្រកាស និង លិខិតជូនដំណឹងដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ :** អគ្គាធិការ , អគ្គនាយកបច្ចេកទេស , នាយិកាខុទ្ទកាល័យ, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ, ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៥ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥

ឧ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចាម_ប្រសិទ្ធ**

<u>ចម្លងជូន :</u>

- ខុទ្ទកាល័យ**សម្តេចនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សោ ណាំហុង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវៈនិតិសម្បទា
- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសហគមន៍អឺរ៉ុបនៅទីក្រុងប្រ៊ុសសែល
- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងភ្នំពេញ
- ទីចាត់ការគយ និងរដ្ឋាករ
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ